# កម្រិតអូទីសឹម

ការធ្វើតេស្តកម្រិតអូទីសឹម (AQ) គឺជាសំណួរវិភាគសម្រាប់វាស់ស្ទង់ពីភាពធ្ងន់ធ្ងរនៃជំងឺអូទីសឹមរបស់បុគ្គលម្នាក់ៗ។ វាត្រូវបានបោះពុម្ពផ្សាយដំបូងនៅឆ្នាំ ២០០១ ដោយ ស៊ីម៉ូន បារុន-ខូហេន (Simon Barron-Cohen) និងសហការីរបស់គាត់នៅមជ្ឈមណ្ឌលស្រាវជ្រាវអូទីសឹមខេមប្រ៊ីដ (Cambridge Autism Research Center)។

សូមជ្រើសរើសចម្លើយណាមួយដែលត្រឹមត្រូវបំផុតក្នុងការពិពណ៌នាលោកអ្នកក្នុងសំណួរនីមួយៗ៖

| | ខ្ញុំយល់ស្របខ្លាំង | ខ្ញុំយល់ស្រប | ខ្ញុំមិនយល់ស្រប | ខ្ញុំមិនយល់ស្របខ្លាំង |
|---|---|---|---|---|
| ១. ខ្ញុំចូលចិត្តធ្វើការជាមួយអ្នកដទៃ ជាជាងធ្វើតែម្នាក់ឯង។ | | | | |
| ២. ខ្ញុំចូលចិត្តធ្វើអ្វីតាមវិធីដដែលៗ។ | | | | |
| ៣. ប្រសិនបើខ្ញុំព្យាយាមស្រមៃអ្វីមួយ វាជាការងាយស្រួលណាស់ក្នុងការបង្កើតរូបភាពស្រម៉ៃនោះក្នុងខួរក្បាលខ្ញុំ។ | | | | |
| ៤. ជារឿយៗ ខ្ញុំតែងផ្តោតអារម្មណ៍យ៉ាងខ្លាំងលើរឿងមួយ ដែលធ្វើឲ្យខ្ញុំភ្លេចអស់រឿងផ្សេងៗទៀត។ | | | | |
| ៥. ខ្ញុំឧស្សាហ៍កត់សម្គាល់សម្លេងតិចៗ នៅពេលដែលអ្នកដទៃមិនកត់សម្គាល់ស្តាប់។ | | | | |
| ៦. ជាធម្មតា ខ្ញុំកត់សម្គាល់ស្លាកលេខរថយន្ត ឬខ្សែរព័ត៌មានស្រដៀងគ្នា។ | | | | |
| ៧. អ្នកដទៃតែងប្រាប់ខ្ញុំថា ពាក្យសម្តីខ្ញុំនិយាយគឺគ្មានសុជីវធម៌ទេ ទោះបីខ្ញុំគិតថាសម្តីខ្ញុំនិយាយមានសុជីវធម៌ក៏ដោយ។ | | | | |
| ៨. នៅពេលខ្ញុំអានរឿង ខ្ញុំអាចស្រម៉ៃបានយ៉ាងងាយអំពីរូបរាងរបស់តួអង្គក្នុងរឿង។ | | | | |
| ៩. ខ្ញុំចាប់អារម្មណ៍នឹងកាលបរិច្ឆេទ។ | | | | |
| ១០. នៅក្នុងក្រុមមនុស្សនៃសង្គម ខ្ញុំអាចតាមដានការសន្ទនារបស់មនុស្សផ្សេងៗគ្នាយ៉ាងងាយស្រួល។ | | | | |
| ១១. ខ្ញុំយល់អំពីស្ថានភាពសង្គមយ៉ាងងាយស្រួល។ | | | | |
| ១២. ខ្ញុំមានទំនោរក្នុងការកត់សម្គាល់ព័ត៌មានលំអិតដែលអ្នកដទៃមិនបានកត់សម្គាល់។ | | | | |
| ១៣. ខ្ញុំប្រាថ្នាចង់ទៅបណ្ណាល័យ ជាជាងពិធីជប់លៀង។ | | | | |
| ១៤. ខ្ញុំគិតថាការប្រឌិតរឿងមានភាពងាយស្រួល។ | | | | |

| | | | | |
|---|---|---|---|---|
| ១៥. ខ្ញុំគិតថា ខ្លួនខ្ញុំចាប់អារម្មណ៍នឹងមនុស្សជាជាងវត្ថុ។ | | | | |
| ១៦. ខ្ញុំមានទំនោរចាប់អារម្មណ៍ខ្លាំងលើរឿងអ្វីមួយ ហើយខ្ញុំអាចនឹងតូចចិត្តប្រសិនបើខ្ញុំមិនអាចធ្វើអ្វីដែលខ្ញុំចាប់អារម្មណ៍នោះ។ | | | | |
| ១៧. ខ្ញុំចូលចិត្តការនិយាយគ្នាលេង។ | | | | |
| ១៨. ពេលខ្ញុំនិយាយ អ្នកដទៃពិបាកនឹងលូកមាត់និយាយ ។ | | | | |
| ១៩. ខ្ញុំចាប់អារម្មណ៍នឹងលេខ។ | | | | |
| ២០. នៅពេលដែលខ្ញុំកំពុងអានរឿង ខ្ញុំពិបាកនឹងគិតអំពីបំណងរបស់តួអង្គក្នុងរឿង។ | | | | |
| ២១. ខ្ញុំមិនចូលចិត្តការអានរឿងប្រឌិតទេ។ | | | | |
| ២២. ខ្ញុំពិបាកនឹងរាប់អានមិត្តថ្មី។ | | | | |
| ២៣. ខ្ញុំតែងតែកត់សម្គាល់ឃើញលំនាំនៃរឿងនានា។ | | | | |
| ២៤. ខ្ញុំប្រាថ្នាចង់ទៅរោងកុន ជាជាងទៅសារមន្ទីរ។ | | | | |
| ២៥. ខ្ញុំមិនអន់ចិត្តទេ បើទម្លាប់ប្រចាំថ្ងៃរបស់ខ្ញុំត្រូវបានអាក់ខាន។ | | | | |
| ២៦. ជារឿយៗ ខ្ញុំមិនដឹងថា តើខ្ញុំត្រូវពីបន្តការសន្ទនាដោយរបៀបណា។ | | | | |
| ២៧. ខ្ញុំយល់ថា វាងាយស្រួលនឹង "យល់ពីខ្លឹមសារបង្កប់" នៅពេលអ្នកផ្សេងនិយាយជាមួយខ្ញុំ។ | | | | |
| ២៨. ជាធម្មតា ខ្ញុំផ្តោតអារម្មណ៍លើរូបភាពទាំងមូលជាជាងព័ត៌មានលម្អិត។ | | | | |
| ២៩. ខ្ញុំពិបាកនឹងចងចាំលេខទូរសព្ទ។ | | | | |
| ៣០. ជាធម្មតា ខ្ញុំមិនកត់សម្គាល់ឃើញការផ្លាស់ប្តូរបន្តិចបន្តួចនៅក្នុងស្ថានភាព ឬរូបរាងរបស់មនុស្សឡើយ។ | | | | |
| ៣១. ខ្ញុំអាចដឹងថា អ្នកដែលកំពុងស្តាប់ខ្ញុំនិយាយមានធុញទ្រាន់ ឬអត់។ | | | | |
| ៣២. ខ្ញុំយល់ថា វាជារឿងងាយស្រួលក្នុងការធ្វើរឿងច្រើនក្នុងពេលតែមួយ ជាជាងធ្វើរឿងតែមួយ។ | | | | |
| ៣៣. នៅពេលខ្ញុំនិយាយតាមទូរសព្ទ ខ្ញុំមិនប្រាកដថាពេលណាជាវេនដែលខ្ញុំត្រូវនិយាយនោះទេ។ | | | | |
| ៣៤. ខ្ញុំចូលចិត្តធ្វើអ្វីដោយឯកឯង។ | | | | |
| ៣៥. ខ្ញុំច្រើនតែជាមនុស្សចុងក្រោយគេ ដែលយល់ពីចំណុចកំប្លែង។ | | | | |
| ៣៦. ខ្ញុំយល់ថា វាងាយស្រួលក្នុងការស្វែងយល់អំពីការគិត ឬអារម្មណ៍របស់អ្នកផ្សេង ដោយគ្រាន់តែមើលមុខពួកគេ។ | | | | |

| | | | | |
|---|---|---|---|---|
| ៣៧. ប្រសិនបើខ្ញុំត្រូវបានកាត់សង្វាក់ដោយកត្តាណាមួយ ខ្ញុំអាចប្តូរទៅធ្វើអ្វីដែលខ្ញុំបានកំពុងធ្វើមុនការកាត់សង្វាក់នេះយ៉ាងឆាប់រហ័ស។ | | | | |
| ៣៨. ខ្ញុំពូកែខាងនិយាយគ្នាលេង។ | | | | |
| ៣៩. អ្នកផ្សេងឧស្សាហ៍ប្រាប់ខ្ញុំថា ខ្ញុំកំពុងតែនិយាយរឿងដដែលៗឥតឈប់ឈរ។ | | | | |
| ៤០. កាលខ្ញុំនៅក្មេង ខ្ញុំធ្លាប់ចូលចិត្តលេងល្បែងពាក់ព័ន្ធនឹងការធ្វើត្រាប់តាមជាមួយក្មេងដទៃទៀត។ | | | | |
| ៤១. ខ្ញុំចូលចិត្តប្រមូលព័ត៌មានអំពីយថាប្រភេទនៃវត្ថុ (ឧទាហរណ៍៖ ប្រភេទរថយន្ត បក្សី រថភ្លើង រុក្ខជាតិ) ។ | | | | |
| ៤២. ខ្ញុំមានការលំបាកក្នុងការស្រម៉ៃថាតើវានឹងទៅជាដូចម្តេច ប្រសិនបើខ្ញុំជាអ្នកផ្សេងវិញ។ | | | | |
| ៤៣. ខ្ញុំចូលចិត្តរៀបចំផែនការសកម្មភាពណាមួយដែលខ្ញុំចូលរួមដោយភាពប្រុងប្រយ័ត្ន។ | | | | |
| ៤៤. ខ្ញុំរីករាយនឹងព្រឹត្តិការណ៍សង្គម។ | | | | |
| ៤៥. ខ្ញុំពិបាកនឹងយល់អំពីបំណងរបស់អ្នកដទៃ។ | | | | |
| ៤៦. បរិយាកាសថ្មីធ្វើឲ្យខ្ញុំស្លន់ស្លោ។ | | | | |
| ៤៧. ខ្ញុំចូលចិត្តជួបមនុស្សថ្មី។ | | | | |
| ៤៨. ខ្ញុំជាអ្នកការទូតល្អ។ | | | | |
| ៤៩. ខ្ញុំមិនពូកែចងចាំថ្ងៃកំណើតរបស់អ្នកដទៃ។ | | | | |
| ៥០. ខ្ញុំគិតថា វាងាយស្រួលណាស់ក្នុងការលេងល្បែងជាមួយកុមារដែលពាក់ព័ន្ធនឹងការធ្វើត្រាប់តាម។ | | | | |

សរុបពិន្ទុរបស់ចម្លើយខ្ញុំ

ប្រភព៖


M Woodbury-Smith. Screening Adults for Asperger Syndrome using the AQ: a Preliminary Study of its Diagnostic Validity in Clinical Practice. 35(3): J Autism Dev Disord 331-335. 2005.

Simon Baron-Cohen, et al. The Autism-Spectrum Quotient (AQ): Evidence from Asperger Syndrome/High-Functioning Autism, Males and Females, Scientists and Mathematicians. 31: J Autism Dev Disord 5-17. 2001.

Dorothy VM Bishop, et al. Using Self-Report to Identify the Broad Phenotype in Parents of Children with Autistic Spectrum Disorders: A Study using the Autism-Spectrum Quotient. 45(8): J Child Psychol Psychiatry 1431-1436. 2004.

https://psychology-tools.com/test/autism-spectrum-quotient